**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**អគ្គលេខាធិការដ្ឋាន**

លេខ : ០០៥ គ.ជ.ប.អគ្គ

ថ្ងៃព្រហស្បតិ៍ ១៣រោច ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមករា ឆ្នាំ២០២៣

# សេចក្តីប្រកាសព័ត៌មាន

## ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង ក្នុងដំណាក់កាលនៃការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង និងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត ឆ្នាំ២០២២

គិតត្រឹមថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ ក្នុងដំណាក់កាលបិទផ្សាយបញ្ជីបោះឆ្នោតដំបូង និងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត ឆ្នាំ២០២២ ក្រុមប្រឹក្សាឃុំ សង្កាត់ (កបឃ.ស) ទូទាំងប្រទេស បានទទួលពាក្យបណ្តឹងសរុបចំនួន **៣៣ បណ្តឹង** គឺពាក្យបណ្តឹងតវ៉ាមានចំនួន **២៩ បណ្តឹង** និងពាក្យបណ្តឹងជំទាស់មានចំនួន ៤ បណ្តឹង។ ដោយឡែកនៅថ្នាក់ គ.ជ.ប និងនៅថ្នាក់ក្រុមប្រឹក្សាធម្មនុញ្ញ ពុំទទួលបានពាក្យបណ្តឹងណាមួយឡើយ។

ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅថ្នាក់ កបឃ.ស៖

| ល.រ | រាជធានី ខេត្ត | ចំនួនពាក្យបណ្តឹង | ដំណោះស្រាយ |
|---|---|---|---|
| ០៣ | កំពង់ចាម | **១ បណ្តឹង**<br>- ប្រជាពលរដ្ឋ ១ បណ្តឹង | - កំពុងដោះស្រាយ ១ បណ្តឹង |
| ០៤ | កំពង់ឆ្នាំង | **២ បណ្តឹង**<br>- ប្រជាពលរដ្ឋ ២ បណ្តឹង | - យល់ព្រមតាមពាក្យបណ្តឹង ២ បណ្តឹង |
| ០៥ | កំពង់ស្ពឺ | **១៣ បណ្តឹង**<br>- ប្រជាពលរដ្ឋ ១៣ បណ្តឹង | - កំពុងដោះស្រាយ ៨ បណ្តឹង<br>- យល់ព្រមតាមពាក្យបណ្តឹង ៥ បណ្តឹង |
| ០៧ | កំពត | **២ បណ្តឹង**<br>- ប្រជាពលរដ្ឋ ២ បណ្តឹង | - កំពុងដោះស្រាយ ១ បណ្តឹង<br>- យល់ព្រមតាមពាក្យបណ្តឹង ១ បណ្តឹង |
| ១២ | ភ្នំពេញ | **៣ បណ្តឹង**<br>- ប្រជាពលរដ្ឋ ៣ បណ្តឹង | - កំពុងដោះស្រាយ ៣ បណ្តឹង |
| ១៤ | ព្រៃវែង | **៤ បណ្តឹង**<br>- ប្រជាពលរដ្ឋ ៤ បណ្តឹង | - យល់ព្រមតាមពាក្យបណ្តឹង ៤ បណ្តឹង |
| ១៥ | ពោធិ៍សាត់ | **២ បណ្តឹង**<br>- ប្រជាពលរដ្ឋ ២ បណ្តឹង | - កំពុងដោះស្រាយ ២ បណ្តឹង |
| ១៧ | សៀមរាប | **១ បណ្តឹង**<br>- ប្រជាពលរដ្ឋ ១ បណ្តឹង | - យល់ព្រមតាមពាក្យបណ្តឹង ១ បណ្តឹង |



អគារ គ.ជ.ប៖ វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ 012 959 666 / 092 105 556 / 012 855 018
NEC Building : St. Ratsaphea, Sangkat Tonle Basac, Khan Chamkar Mon, Phnom Penh, Kingdom of Cambodia អ៊ីមែល ៖ info@nec.gov.kh

| ល.រ | រាជធានី ខេត្ត | ចំនួនពាក្យបណ្ដឹង | ដំណោះស្រាយ |
|---|---|---|---|
| ២១ | តាកែវ | ១ បណ្ដឹង<br>- ប្រជាពលរដ្ឋ ១ បណ្ដឹង | - កំពុងដោះស្រាយ ១ បណ្ដឹង |
| ២៣ | ប៉ៃលិន | ៣ បណ្ដឹង<br>- ប្រជាពលរដ្ឋ ៣ បណ្ដឹង | - កំពុងដោះស្រាយ ១ បណ្ដឹង<br>- យល់ព្រមតាមពាក្យបណ្ដឹង ២ បណ្ដឹង |
| ២៥ | ត្បូងឃ្មុំ | ១ បណ្ដឹង<br>- ប្រជាពលរដ្ឋ ១ បណ្ដឹង | - យល់ព្រមតាមពាក្យបណ្ដឹង ១ បណ្ដឹង |
| **សរុប** | | ៣៣ បណ្ដឹង<br>- ប្រជាពលរដ្ឋ ៣៣ បណ្ដឹង | - កំពុងដោះស្រាយ ១៧ បណ្ដឹង<br>- យល់ព្រមតាមពាក្យបណ្ដឹង ១៦ បណ្ដឹង |

ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងតវ៉ា ឬ/និងជំទាស់ក្នុងដំណាក់កាលនៃការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង និងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត ឆ្នាំ២០២២ មាន ៣ ថ្នាក់ រួមមាន៖

- ការដាក់ និងការទទួលពាក្យបណ្ដឹងនៅ កបឃ.ស មានរយៈពេល ១០ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ហើយការដោះស្រាយពាក្យបណ្ដឹងមានរយៈពេល ៣ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្ដឹង
- ការដាក់ និងការទទួលពាក្យបណ្ដឹងនៅ គ.ជ.ប មានរយៈពេល ៥ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្ដីសម្រេច (ទ.១២០៣) របស់ កបឃ.ស ហើយការដោះស្រាយពាក្យបណ្ដឹងមានរយៈពេល ៥ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្ដឹង
- ការដាក់ និងការទទួលពាក្យបណ្ដឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ មានរយៈពេល ៥ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្ដីសម្រេច (ទ.១២០៣) របស់ គ.ជ.ប ហើយការដោះស្រាយពាក្យបណ្ដឹងមានរយៈពេល ១០ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្ដឹង។

ដំណើរការនៃការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង និងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោតនៅតាមឃុំ សង្កាត់ទូទាំងប្រទេស ឆ្នាំ២០២២ បានប្រព្រឹត្តទៅដោយរលូនល្អ ក្នុងបរិយាកាសស្ងប់ស្ងាត់គ្មានអំពើហិង្សា និងគ្មានការគំរាមកំហែង។



អគារ គ.ជ.ប៖ វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ៖ 012 959 666 / 092 105 556 / 012 855 018
NEC Building : St. Ratsaphea, Sangkat Tonle Basac, Khan Chamkar Mon, Phnom Penh, Kingdom of Cambodia អ៊ីម៉ែល៖ info@nec.gov.kh